**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

លេខៈ ២៦៥៤ ប្រ.ក បស្ថ

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «ចាក់អង្រែ» នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ស្ថិតនៅភូមិបាក់កាំ ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៨៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.**_

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ«**ចាក់អង្រែ**» នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ស្ថិតនៅភូមិបាក់កាំ ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ«**ចាក់អង្រែ**» នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង មានផ្ទៃដីសរុបទំហំ **១,១៦៦ ហិកតា** (មួយពាន់មួយរយហុកសិបប្រាំមួយហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 484146 | 1519257 | 6 | 484905 | 1522772 |
| 2 | 485437 | 1520234 | 7 | 482906 | 1522574 |
| 3 | 487633 | 1521897 | 8 | 482808 | 1521793 |
| 4 | 489111 | 1523015 | 9 | 483021 | 1521166 |
| 5 | 487377 | 1522989 | | | |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ«**ចាក់អង្រែ**» ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ«**ចាក់អង្រែ**» នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ«**ចាក់អង្រែ**» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ«**ចាក់អង្រែ**» ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិបាក់អង្រែ នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង

## ភូមិសាស្ត្រភូមិបាក់កាំ ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ផ្ទៃដី១១៦៦ហិកតា

ឧបសម្ព័ន្ធ : ប្រកាសលេខ ២៦៥ ......... ចុះថ្ងៃទី ៣១ ......... ខែ ឧសភា ......... ឆ្នាំ ២០២០ ......... របស់ក្រសួងបរិស្ថាន




និយាមកាព្រំប្រទល់សហគមន៍

តំបន់ការពារធម្មជាតិបាក់អង្រែ ភូមិបាក់កាំ ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

| ID | X | Y |
|---|---|---|
| 1 | 484146 | 1519257 |
| 2 | 485437 | 1520234 |
| 3 | 487633 | 1521897 |
| 4 | 489111 | 1523015 |
| 5 | 487377 | 1522989 |
| 6 | 484905 | 1522772 |
| 7 | 482906 | 1522574 |
| 8 | 482808 | 1521793 |
| 9 | 483021 | 1521166 |

**សញ្ញាសំគាល់**

- ចំនុចព្រំសហគមន៍
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់សហគមន៍

| | |
|---|---|
| ចំនុចព្រំសហគមន៍ | វាលស្មៅ |
| ទន្លេ ស្ទឹង | ទីក្រុង និងប្រជុំជន |
| ខ្សែរយៈកម្ពស់ | ព្រៃដាំឡើងវិញ |
| ព្រំប្រទល់សហគមន៍ | តំបន់វាលភក់ |
| ដំណាំប្រចាំឆ្នាំ | វារីវប្បកម្ម |
| វាលស្រែ | ដីគ្មានគម្របរុក្ខជាតិ |
| ដំណាំពនេចរ | ដំណាំឧស្សាហកម្ម |
| ចំការឈើហូបផ្លែ | ព្រៃបៃតង |
| ព្រៃល្បោះ | ព្រៃស្រល់ |
| ព្រៃស្រោង | ព្រៃគម្ពោត |

0 0.5 1 2 Km

Map Coordinate System
Unit: Meter
System: UTM, Zone 48N
Datum: WGS 1984

មាត្រដ្ឋាន ១:៤០ ០០០